**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**

លេខ: ៤៧៦ ៧១៧

| ទីស្តីការគណៈរដ្ឋមន្ត្រី | |
|---|---|
| ចូល | លេខ.....897..... |
| | ថ្ងៃទី...17...ខែ...03...ឆ្នាំ...2017 |
| | ម៉ោង.....3h00..... |

| ខុទ្ទកាល័យសម្តេចតេជោ (វិមាន ...) | |
|---|---|
| ចូល | លេខ .................... |
| | ថ្ងៃទី .....17-3-2017..... |
| | ម៉ោង .....3h30..... |

រាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៧

**សូមគោរពជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី**

**នៃព្រះរាជាណាចក្រកម្ពុជា**

*ជាទីគោរពដ៏ខ្ពង់ខ្ពស់*

**កម្មវត្ថុ:** សូមគោរពស្នើសុំគោលការណ៍ដោះស្រាយករណីទារក ដែលកើតដោយការជួល ស្ត្រីខ្មែរឲ្យពពោះជំនួស ដើម្បីយកទារកចេញទៅចិញ្ចឹមនៅក្រៅប្រទេស ។

**យោង:** ស្មារតីនៃកិច្ចប្រជុំអន្តរក្រសួង នាថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ២០១៧ នៅក្រសួងមហាផ្ទៃ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមគោរពជម្រាបជូន **សម្តេចតេជោនាយករដ្ឋមន្ត្រី** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា៖ ថ្មីៗនេះ នៅក្នុងព្រះរាជាណាចក្រកម្ពុជា មានលេចចេញនូវបាតុភាពជនបរទេស ជួលស្ត្រីខ្មែរឲ្យពពោះ ដើម្បីយកទារកទៅប្រទេសខ្លួន។ ដោយមានក្តីបារម្ភ ចំពោះបាតុភាពនៃការជួលពពោះ ដែលកាន់តែរីករាលដាលច្រើនឡើង និងអាចធ្វើឲ្យកម្ពុជាក្លាយទៅជាទីផ្សារអាជីវកម្មនៃការជួលពពោះ និងនាំទារកចេញដោយខុសច្បាប់ ឬជួញដូរទារក ដែលប្រទេសជាច្រើនក្នុងពិភពលោកបាន និងកំពុងតែរឹតបន្តឹង ។ សមត្ថកិច្ចកម្ពុជាបានបើកការស៊ើបអង្កេត និងឈានទៅដល់ការបង្ក្រាបករណីនេះកាល ពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៦ ដោយបានឃាត់ខ្លួនជនសង្ស័យជាអន្តរការីចំនួន ៣នាក់ ដែលម្នាក់ជាជនជាតិអូស្ត្រាលី និងពីរនាក់ទៀតជាជនជាតិខ្មែរ ដោយអនុលោមតាមមាត្រា៣៣២ នៃក្រមព្រហ្មទណ្ឌ។ ជនសង្ស័យទាំងបីរូប កំពុងស្ថិតនៅក្រោមយុត្តាធិការសាលាដំបូងរាជធានីភ្នំពេញ។ ការស៊ើបអង្កេតបានធ្វើបន្តទៀតដើម្បីស្វែងរកក្រុមដទៃ ដែលបានធ្វើសកម្មភាពតាមបណ្តាខេត្តផ្សេងៗ តែគេបានដឹងខ្លួនជាមុនហើយបង្វែរទិសទៅកាន់ប្រទេសផ្សេង ។

តាមរបាយការណ៍ពីអគ្គនាយកដ្ឋានអន្តោប្រវេសន៍ កន្លងមក មានទារកចំនួន ៣៣នាក់ ដែលទទួលបានសញ្ជាតិបរទេសពីស្ថានទូតរបស់សាម៉ីខ្លួនជនបរទេសជាអ្នកស្នើសុំ បានចុះបញ្ជីស្នើសុំទិដ្ឋាការនាំចេញទៅបរទេសរួចហើយ ក្នុងនោះ ជាទារកកើតពីម្តាយជាជនជាតិខ្មែរចំនួន ២៨ នាក់ និងពីជនជាតិថៃ ចំនួន ៥ នាក់។ ទន្ទឹមនឹងពេលដែល សមត្ថកិច្ចបង្ក្រាបករណីនេះ ស្ថានទូតនានាដែលមានជនជាតិរបស់ខ្លួនពាក់ព័ន្ធនឹងករណីពពោះនេះ បានស្នើសុំឲ្យក្រសួងការបរទេស ក្រសួងមហាផ្ទៃធ្វើអន្តរាគមន៍ លើសំណើសុំយកទារកដែលបានកើតរួចហើយ ចេញទៅប្រទេសរបស់ខ្លួន ដោយអះអាងថាខ្លួនជាឪពុកតាមរយៈការបញ្ជាក់ពីរបាយការណ៍កោសល្យវិច្ច័យលើ DNA។ នៅមានឯកសារ ១០ច្បាប់ទៀតដែលបានបញ្ជូនមកក្រសួងមហាផ្ទៃ គឺពីស្ថានទូតអូស្ត្រាលី ស្ថានទូតអាមេរិក ស្ថានទូតកាណាដា ស្ថានទូតអង់គ្លេស និងស្ថានទូតជប៉ុន និងមានស្ត្រីដែលបាននិងកំពុង

តែពពោះ ក្នុងអំឡុងពេលដែលមិនទាន់មានការបង្ក្រាបមួយចំនួនទៀត ដែលមិនទាន់អាចកំណត់ចំនួនបានពិតប្រាកដ។

ដើម្បីពិនិត្យរកដំណោះស្រាយសមស្របចំពោះករណីនេះ ខ្ញុំបានចាត់ឲ្យលោកជំទាវរដ្ឋលេខាធិការទទួលបន្ទុកអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កោះប្រជុំជំនាញអន្តរក្រសួងជាបន្តបន្ទាប់ ។ ចុងក្រោយ ខ្ញុំបានដឹកនាំកិច្ចប្រជុំមួយកាលពីថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៧ ដោយមានការចូលរួមពីថ្នាក់ដឹកនាំក្រសួង អង្គភាពពាក់ព័ន្ធសំខាន់ៗ ជាពិសេស ក្រសួងយុត្តិធម៌ ក្រសួងសុខាភិបាល ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ក្រសួងកិច្ចការនារី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងអប់រំ អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកដ្ឋាន អត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ អគ្គអយ្យការអមសាលាឧទ្ធរណ៍ តុលាការរាជធានីភ្នំពេញ ។ល។ ដោយហេតុថា បច្ចុប្បន្ន ព្រះរាជាណាចក្រកម្ពុជាពុំទាន់មានច្បាប់ដោយឡែក ដែលចែងអំពីការគ្រប់គ្រងការពពោះជំនួសឱ្យបានគ្រប់ជ្រុងជ្រោយនៅឡើយទេ។ តាមការស្រាវជ្រាវច្បាប់បច្ចុប្បន្ន យើងមានក្រមព្រហ្មទណ្ឌដែលចែងក្នុងមាត្រា ៣៣២ ដោយផ្តន្ទាទោសសកម្មភាពធ្វើជាអន្តរការីទាក់ទងនឹងការពពោះ ដើម្បីជាថ្នូរនឹងកម្រៃ ដាក់ពន្ធនាគារពី ១ខែ ទៅ ៦ខែ និងពិន័យជាប្រាក់ពី ១សែនរៀល ទៅ ១លានរៀល។ ចំពោះស្ត្រីពពោះ និងឪពុកម្តាយដែលជាម្ចាស់មេជីវិត គឺមិនមានការចែងផ្តន្ទាទោសនោះទេ។ ដោយឡែកចំពោះការកំណត់អំពីទំនាក់ទំនងភាពជាឪពុកម្តាយ និងទារកដែលកើតតាមរយៈការពពោះនេះ គឺគ្រប់គ្រងដោយក្រមរដ្ឋប្បវេណី។ យោងតាមមាត្រា ៩៨៧ នៃក្រមរដ្ឋប្បវេណីនេះ ស្ត្រីពពោះត្រូវបានកំណត់ជាម្តាយដោយពេញច្បាប់របស់ទារកដែលកើតមក ទោះបីមេជីវិតជារបស់អ្នកផ្សេងក៏ដោយ។ ដូចនេះ តាមផ្លូវច្បាប់ កូនដែលកើតពីការពពោះមានម្តាយជាស្ត្រីពពោះដែលជាខ្មែរ និងមានឪពុកជាជនបរទេស ទារកដែលកើតមក គឺមានសញ្ជាតិខ្មែរតាមម្តាយជាជនជាតិខ្មែរផង និងសញ្ជាតិបរទេសតាមសញ្ជាតិរបស់ឪពុកផង។ ក្នុងពេលរង់ចាំការរៀបចំ និងអនុម័តច្បាប់ស្តីពីការពពោះ ការដោះស្រាយបញ្ហាចំពោះមុខខាងលើ គប្បីផ្អែកលើគោលការណ៍ចម្បងពីរ គឺ៖

(ទី១) ជានានូវការអនុវត្តតួនាទីរបស់អាជ្ញាធររដ្ឋក្នុងការការពារសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់ពលរដ្ឋខ្លួន ជាពិសេស លើការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីកុំឱ្យកម្ពុជាក្លាយជាគោលដៅនៃការធ្វើអាជីវកម្មពពោះជំនួស និង

(ទី២) ធានាផលប្រយោជន៍របស់ទារក ដែលកកំណើត ឬដែលបានកើតមកហើយ។ ផ្អែកលើគោលការណ៍នេះ អង្គប្រជុំយល់ឃើញថា ដំណោះស្រាយចំពោះបញ្ហាខាងលើ ក្នុងពេលចំពោះមុខត្រូវអនុវត្តទៅតាមច្បាប់ត្រឹមកម្រិតច្បាប់ដែលយើងមានបច្ចុប្បន្ន និងដាក់ចេញវិធានការរឹតបន្តឹងមួយចំនួន ដូចខាងក្រោម ៖

<u>វិធានការទី១</u>- ការនាំយកទារកចេញទៅប្រទេសក្រៅអាចអនុញ្ញាតដើម្បីជាផលប្រយោជន៍ សម្រាប់ទារក ប៉ុន្តែការនាំយកចេញនេះ ត្រូវអនុវត្តដោយអនុលោមតាមច្បាប់រដ្ឋប្បវេណីរបស់កម្ពុជាគឺ៖

- ក្នុងករណីស្ត្រីពពោះមានចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ កូនដែលកើតមកត្រូវសន្មតថាជាកូន របស់ប្តីនៃស្ត្រីពពោះ។ ឪពុកដែលជាម្ចាស់មេជីវិតចាំបាច់ត្រូវប្តឹងទៅតុលាការដើម្បី

ទាមទារបិតុភាព(ភាពជាឪពុក)លើទារកនោះតាមផ្លូវច្បាប់ដោយបង្ហាញភស្តុតាងកោសល-វិច្ច័យលើDNA។

- ក្នុងករណីស្ត្រីពពោះនៅលីវ ឬពុំមានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ ឪពុកដែលជាម្ចាស់មេជីវិតត្រូវប្ដឹងទៅតុលាការសុំសិទ្ធិគ្រប់គ្រងកូន ដើម្បីអាចនាំកូននោះទៅក្រៅប្រទេសកម្ពុជាបាន។ ការសម្រេចអនុញ្ញាតនឹងអាចធ្វើបានដោយតុលាការ ប្រសិនស្ត្រីពពោះព្រមព្រៀងប្រគល់កូននោះឱ្យទៅឪពុកជាម្ចាស់មេជីវិតគ្រប់គ្រង។ កិច្ចសន្យាពពោះ មិនអាចយកមកធ្វើជាមូលដ្ឋានកំណត់ការព្រមព្រៀងនេះបានទេ ព្រោះជាកិច្ចសន្យាខុសច្បាប់។
- ដោយឡែក ចំពោះវិធានការព្រហ្មទណ្ឌ គឺនៅតែបន្តអនុវត្តចំពោះករណីជនល្មើស ដែលជាអន្តរការីនៃការពពោះជំនួស ស្របតាមមាត្រា ៣៣២ នៃក្រមព្រហ្មទណ្ឌ។

<u>វិធានការទី២-</u> ដើម្បីទប់ស្កាត់ការកើតឡើងនូវករណីថ្មី និងការពារមិនឲ្យកម្ពុជា ក្លាយជាគោលដៅនៃអាជីវកម្មជួញដូរទារក ដំណោះស្រាយនេះ នឹងត្រូវបានកំណត់តែចំពោះទារកដែលមានកំណើតក្នុងផ្ទៃរួចហើយ គិតចាប់ពីថ្ងៃចេញផ្សាយគោលការណ៍នេះតទៅរហូតដល់រយៈពេល៩ខែ ១០ថ្ងៃក្រោយ ដើម្បីទុកឱកាសឲ្យទារកដែលមានកំណើតរួចហើយ ទទួលបានការការពារ ហើយទន្ទឹមនឹងនេះ ការចេញប្រកាសហាមឃាត់ការពពោះជំនួស គឺជាការចាំបាច់ អមដោយការរឹតបន្តឹងវិធានការរដ្ឋបាល ពិសេស ការត្រួតពិនិត្យតាមគ្លីនិកមួយចំនួនដែលមាន បច្ចេកវិទ្យាពាក់ព័ន្ធនឹងការពពោះ។

<u>វិធានការទី៣-</u> ដើម្បីដោះស្រាយបញ្ហាពពោះនេះឱ្យបានគ្រប់ជ្រុងជ្រោយ និងចប់សព្វគ្រប់ គួរជំរុញការរៀបចំ និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពី «ការគ្រប់គ្រងការពពោះជំនួស» ឱ្យបានឆាប់ ហើយការរៀបចំច្បាប់នេះ ចាំបាច់ត្រូវសិក្សាឱ្យបានគ្រប់ទិដ្ឋភាព ដែលដោះស្រាយ យថាភាពនានា ដែលអាចកើតមានឡើងដោយសារភាពស្មុគស្មាញនៃបញ្ហា និងការវិវត្តកាន់តែជឿនលឿននូវបច្ចេកវិទ្យាក្នុងវិស័យនេះ ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ ខ្ញុំសូម **សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** មេត្តាពិនិត្យ និងសម្រេចជាគោលការណ៍ដោយអនុគ្រោះ ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ប្រធាន គ.ជ.ប.ជ**

**សម្តេចក្រឡាហោម ស ខេង**